**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យ
# ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

--------

អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា សូមសម្តែង នូវការខកចិត្ត ចំពោះសេចក្តីថ្លែងការណ៍របស់ប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា ចេញផ្សាយនៅថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១៧ ដែលបាននិយាយយោងជាពិសេសដល់ការសម្រេចរបស់តុលាកាកម្ពុជាក្នុងការពន្យារយៈពេលឃុំឃាំង ជនត្រូវចោទ ដែលនេះជាកិច្ចការផ្ទៃក្នុងទាំងស្រុងរបស់កម្ពុជា។

សេចក្តីថ្លែងការណ៍ខាងលើនេះ ជាការរំលោភបំពានយ៉ាងច្បាស់លើអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីទំនាក់ទំនងការទូត មាត្រា៤១ (១) ដែលចែងថា រាល់បេសកកម្មការទូតទាំងអស់មានកាតព្វកិច្ចគោរពច្បាប់ និងបទបញ្ញានានារបស់រដ្ឋដែលខ្លួនតាំងនៅ ហើយពួកគេមានកាតព្វកិច្ចមិនលូកដៃជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋនោះឡើយ។

អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិសូមជម្រាបជាសាធារណៈថា ការសម្រេចរបស់តុលាកាគឺស្របទៅតាមក្រមនិតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា មាត្រា ២០៥ និងមាត្រា ២០៨។ តាមច្បាប់ ចៅក្រមស៊ើបអង្កេតអាចសម្រេចពន្យាការឃុំឃាំងមុនសវនាការ២ដងក្នុងរយៈពេល៦ ខែ ក្នុង១ដង។

អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្នើប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា គោរពឲ្យបានហ្មត់ចត់ចំពោះកាតព្វកិច្ចរបស់ខ្លួន ដូចដែលមានចែងនៅក្នុងអនុសញ្ញាខាងលើ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១៧

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

Scanned by CamScanner